ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ.១៨៨៨.....សហវ.-ប្រកាស

ប្រកាស
ស្តីពី
ការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់ការបង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
និងជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៤/អនក្រ/បក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.ប្រក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

ប្រការ ១ .-

បង្កើតក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា។

ប្រការ ២ .-

ក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា មានសមាសភាពដូចតទៅ÷

១	ឯកឧត្តម	**រស់ សីលវ៉ា**	អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ប្រធាន
២	ឯកឧត្តម	**កៅ ថាច**	អគ្គនាយករង គណៈកម្មការមូលបត្រកម្ពុជា	អនុប្រធាន
៣	លោក	**មុី វ៉ាន់**	ប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	អនុប្រធាន
៤	លោក	**ថៃ សភា**	ប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និង សហប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា	អនុប្រធាន
៥	លោក	**សុខ សារាវុឌ្ឍ**	ប្រធាននាយកដ្ឋានថវិកា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៦	លោក	**គីម ផល្លា**	ប្រធាននាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៧	លោក	**ជាន់ ផល្លា**	ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៨	លោក	**រ័ត្ន សុវណ្ណនរៈ**	ប្រធាននាយកដ្ឋានត្រួតពិនិត្យឯកសារ នៃធនាគារជាតិនៃកម្ពុជា	សមាជិក
៩	លោក	**រស់ ភីរុណ**	អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១០	លោក	**ប៊ូ ច័ន្ទភីរ៉ូ**	អនុប្រធាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
១១	លោក	**ឃ្វូ វុឌ្ឍី**	អនុប្រធាននាយកដ្ឋានស្រាវជ្រាវសេដ្ឋកិច្ច និង សហប្រតិបត្តិការ នៃធនាគារជាតិនៃកម្ពុជា	សមាជិក

១២	លោក	បាន លីម	អនុប្រធាននាយកដ្ឋាននីតិកម្ម នៃធនាគារជាតិនៃកម្ពុជា	សមាជិក
១៣	លោក	ឃុន គីមលៀង	ប្រធានការិយាល័យត្រួតពិនិត្យលើឯកសារ នៃគណៈកម្មការមូលបត្រកម្ពុជា	សមាជិក
១៤	លោក	គុយ បញ្ញា	មន្ត្រីនាយកដ្ឋានត្រួតពិនិត្យទីផ្សារមូលបត្រ នៃគណៈកម្មការមូលបត្រកម្ពុជា	សមាជិក
១៥	លោក	ឃុន វាសនា	មន្ត្រីនាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល អភិវឌ្ឍន៍ ទីផ្សារមូលបត្រ និងទំនាក់ទំនងអន្តរជាតិ នៃគណៈកម្មការមូលបត្រកម្ពុជា	សមាជិក
១៦	លោក	ឆឺង ចន្ថា	ប្រធានការិយាល័យទីផ្សារហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	លេខាធិការ

ប្រការ ៣ .-

ក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា មានភារកិច្ចដូចខាងក្រោម÷

- វាយតម្លៃអំពីសភាពការណ៍ និងការវិវត្តនៃស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោក
- សិក្សា និងវិភាគស្ថានភាពវិបត្តិហិរញ្ញវត្ថុដែលអាចកើតមានឡើងជាយថាហេតុ ទាំងនៅក្នុងសកលលោក តំបន់ និងក្នុងប្រទេស និងផលប៉ះពាល់មកលើកម្ពុជា
- សិក្សា និងលើកអនុសាសន៍អំពីការរៀបចំយន្តការ ដើម្បីទប់ស្កាត់ និងដោះស្រាយវិបត្តិក្នុងវិស័យហិរញ្ញវត្ថុ និង
- ទំនាក់ទំនង និងធ្វើកិច្ចសហប្រតិបត្តិការជាមួយស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិ និងដៃគូពាក់ព័ន្ធផ្សេងទៀតក្នុងការអភិវឌ្ឍការងារក្នុងក្របខ័ណ្ឌនេះ។

ប្រការ ៤ .-

ក្រុមការងារសិក្សាស្រាវជ្រាវសម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជា មាននាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជាលេខាធិការដ្ឋាន និងមានការិយាល័យទីផ្សារហិរញ្ញវត្ថុនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុជាជំនួយការ។

ប្រការ ៥ .-

សមាជិកនៃក្រុមការងារសិក្សាស្រាវជ្រាវ សម្រាប់បង្កើតយន្តការគ្រប់គ្រងវិបត្តិរបស់វិស័យហិរញ្ញវត្ថុកម្ពុជាទាំងអស់ ត្រូវចូលរួមប្រជុំតាមការកោះអញ្ជើញរបស់ប្រធាន ឬអនុប្រធាន (តាមការចាត់តាំងរបស់ប្រធាន) ករណីប្រធានអវត្តមាន។

ប្រការ ៦ .-

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា អគ្គនាយកគណៈកម្មការមូលបត្រកម្ពុជា និងសាមីខ្លួនដូចមានក្នុងប្រការ២ មានភារកិច្ចអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ២០១៣

តារា លង់

ចម្លងជូន

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាប"
- ដូចប្រការ២
  " ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ